ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

សាលក្រមលេខ ១២ "ក"
ចុះថ្ងៃទី ០៧ ខែ ០៦ ឆ្នាំ ២០១១

នាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តតាកែវ

សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៣
ចុះថ្ងៃទី ០៦ ខែ ០៥ ឆ្នាំ២០១០

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ប្រធាន សាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តតាកែវ

- ដើម្បីជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] សក្តដា ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅកំណើត និងបច្ចុប្បន្នភូមិ [redacted] របររកស៊ីធ្វើស្រែ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) មានកូន០១នាក់ កំរិតវប្បធម៌ថ្នាក់ទី៨ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

- **ជាប់ចោទពីបទ :** បង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិអញ្ចាញ ឃុំជ័យជោគ ស្រុកបុរីជលសារ ខេត្តតាកែវ កាលពីថ្ងៃទី ០៨-០៣-២០១០ ។

-បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅភូមិ [redacted] ។ ប្តឹងទាមទារថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន ១០.០០០.០០០៛ (ដប់លានរៀល) ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី ០៨ ខែ ០៣ ឆ្នាំ ២០១០ វេលាម៉ោង១១ថ្ងៃត្រង់ នៅភូមិអញ្ចាញ ឃុំជ័យជោគ ស្រុកបុរីជលសារ ខេត្តតាកែវ មានអំពើល្មើសកើតឡើងដែលបង្កឡើងដោយជនល្មើសឈ្មោះ [redacted] សក្តដា បានយកដែកគោលវែង (គោយន្ត) វាយទៅលើឈ្មោះ [redacted] ចាន់ធឿន និង [redacted] ចាន់ថេន ជាបងប្អូន ខណៈដែលពួកគេទាំងបីនាក់ឈ្មោះ

ប្រកែកគ្នាពីរឿងបើកគោយន្តបាំងផ្លូវ ។

- ក្រោយពេលកើតហេតុរួចភាគីទាំងពីរបានប្តឹងសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនមកតុលាការរហូតសព្វថ្ងៃ ។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៩៦ ចុះថ្ងៃទី ២០ ខែ ០៤ ឆ្នាំ ២០១១ ។

- បានឃើញដីកាជូនរឿងទៅជំនុំជំរះលេខ ១៦៤ ចុះថ្ងៃទី ០៣ ខែ ០៥ ឆ្នាំ ២០១១ ។

- បានឃើញដីកាសំរេចលើកលែងចោទប្រកាន់លេខ ១៦៥ ចុះថ្ងៃទី ០៣ ខែ ០៥ ឆ្នាំ ២០១១ ។

- បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១០១ ចុះថ្ងៃទី ០៦ ខែ ០៥ ឆ្នាំ ២០១១ ។

## <u>នាពេលសវនាការ</u>

+ ជនជាប់ចោទឈ្មោះ [redacted] សក្កដា បានចូលមកឆ្លើយថា កាលពីថ្ងៃទី ០៨ ខែ ០៣ ឆ្នាំ ២០១០ ថ្ងៃត្រង់ខ្លួនពិតជាបានវាយទៅលើឈ្មោះ [redacted] ចាន់ធឿន និងឈ្មោះ [redacted] ចាន់ថេន មែន ។ ការវាយនេះដោយសារពួកគេទាំងពីរនាក់ជេរតេះដៀលចំពោះខ្លួន ។

តែនៅពេលប្រតាយប្រតប់គ្នាឈ្មោះ [redacted] ចាន់ធឿន និងឈ្មោះ [redacted] ចាន់ថេន បានយកដែកម៉ាក់វេនគោយន្តវាយមកលើខ្លួនត្រូវត្រង់ក្បាលបណ្តាលអោយមានរបួសដូចគ្នា ។ ខ្លួនវាយទៅលើ [redacted] ចាន់ធឿន គឺវាយនិងដៃ មិនបានយកម៉ាក់វេនគោយន្តវាយដូចការចោទប្រកាន់ឡើយ ។

ខ្ញុំមានរបួសត្រង់ក្បាលព្យាបាលរយៈពេល០៦ថ្ងៃទើបជា គឺនៅមន្ទីរពេទ្យខេត្តតាកែវ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានចូលមកឆ្លើយថាខ្លួនត្រូវជាឪពុករបស់ឈ្មោះ [redacted] ចាន់ធឿន និង [redacted] ចាន់ថេន សកម្មភាពពេលកើតហេតុខ្លួនមិនបានឃើញទេ ។ លុះពេលកើតហេតុរួចទើបឈ្មោះ ពេជរត់មកប្រាប់ខ្ញុំថា កូនខ្ញុំទាំងពីរនាក់នេះត្រូវបានឈ្មោះ សក្កដា ហៅជាត វាយជិតស្លាប់ហើយ ។ ពេលខ្ញុំទៅដល់ឃើញកូនខ្ញុំឈ្មោះ [redacted] ចាន់ធឿន របួសដេកសន្លាប់ ឯកូនឈ្មោះ [redacted] ចាន់ថេន មានរបួសត្រង់មាត់បន្តិចបន្តួច ។

- ពេលនាំកូនដល់ពេទ្យពិនិត្យឃើញរបួស [redacted] ចាន់ធឿន រង្គើធ្មេញតែមិនបាក់ទេ ដេរមុខរបួស៦ថ្នេរព្យាបាលរយៈពេល០៧ថ្ងៃទើបជាសះស្បើយ ។

ក្នុងរឿងនេះខ្លួនទាមទារថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន ១០.០០០.០០០៛ ( ដប់លានរៀល ) ។

- ជនរងគ្រោះឈ្មោះ [redacted] ចាន់ធឿន បានចូលមកឆ្លើយថា នៅថ្ងៃកើតហេតុដោយសារថាឈ្មោះ [redacted] សក្កដា បានចតគោយន្តរបស់គេរាំងផ្លូវ ខ្លួននិយាយថាយីអាឈ្លើយ រួចបើកគោយន្តរបស់ខ្លួនមកផ្ទះ ដល់ពាក់កណ្តាលផ្លូវឈ្មោះ [redacted] សក្កដា តាមក្រោយមកទាន់ខ្លួនហើយ ឃាត់សួរនាំរួចទាញយកម៉ាក់វេនគោយន្តមកវាយខ្លួនតែម្តង ក៏ត្រូវមាត់បែក និងរង្គើធ្មេញ ដោយ [redacted] សក្កដា ដៃស្តាំកាន់ម៉ាក់វេន និងវាយខ្ញុំត្រូវថ្ពាល់ខាងស្តាំ ក្បាលខ្ញុំផង និងវាយម្តងទៀតរហូតដល់សន្លាប់ ។ ខ្ញុំត្រូវបានប្អូនខ្ញុំឈ្មោះ [redacted] ចាន់ថេន និងឪពុកខ្ញុំយកទៅពេទ្យ ។

+ ជនរងគ្រោះឈ្មោះ [redacted] ចាន់ថេន បានចូលមកឆ្លើយថា នៅថ្ងៃកើតហេតុ ពេលកើតហេតុខ្លួនមិនបាន

ឃើញទេ តែថ្ងៃនោះពេលដែលខ្លួនបើកគោយន្តរបស់ខ្លួនមកតាមក្រោយបងប្រុសរបស់ខ្លួន ( [redacted] ចាន់ធឿន ) តាមផ្លូវខ្ញុំបានឃើញបងប្រុសខ្ញុំដួល ហើយឈ្មោះ [redacted] សក្កដា កាន់មាំភាវេទត្បូងដៃវាយទៅលើបងខ្ញុំបន្ថែម ។ ពេលខ្ញុំឈប់សួរនាំឈ្មោះ [redacted] សក្កដា បានស្ទុះមកវាយខ្ញុំត្រូវត្រង់បបូរមាត់បែកទៀត ។

+ សាក្សីឈ្មោះ [redacted] វណ្ណា បានចូលមកឆ្លើយថា ខ្លួនត្រូវជាប្អូនបង្កើតរបស់ [redacted] សក្កដា ។ ថ្ងៃកើតហេតុ ខ្លួនបើកគោយន្តខ្លួនទី៥ មកតាមក្រោយដល់ពាក់កណ្តាលផ្លូវឃើញបងខ្ញុំឈ្មោះ [redacted] សក្កដា ដួលលើកង់គោយន្ត ដោយសារតែឈ្មោះ [redacted] ចាន់ធឿន និង [redacted] ចាន់ថេន វាយគាត់ត្រូវត្រង់ក្បាល និងដៃដោយខ្លួនមិនបានឃើញបងប្រុសខ្ញុំវាយអ្នកទាំងពីរ និងមាំភាវេទនទេ ។

+ តំណាងអយ្យការបានសន្និដ្ឋានថា ផ្អែកតាមការសួរដេញដោលឃើញថា តាមចម្លើយសារភាពរបស់ជនជាប់ចោទស្របនិងចម្លើយជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងវិញ្ញាបនបត្ររបស់ពេទ្យ កំណត់បានថាឈ្មោះ [redacted] សក្កដា ពិតជាបានបង្ករបួសទៅលើឈ្មោះ [redacted] ចាន់ធឿន និងម៉ូវ ចាន់ថេន ប្រាកដមែន ។ ចំណែកឈ្មោះ [redacted] ចាន់ធឿន និង [redacted] ចាន់ថេន ដែលបានតបតវិញ គឺគ្រាន់តែការពារខ្លួនស្របច្បាប់តែប៉ុណ្ណោះ ។

ដូច្នេះសុំអោយតុលាការសំរេចផ្តន្ទាទោសឈ្មោះ [redacted] សក្កដា តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

+ សំណូមពរសំដីចុងក្រោយបង្អស់របស់ជនជាប់ចោទបានសុំអោយតុលាការជួយរកយុត្តិធម៌ដល់ខ្លួន ព្រោះថា ខ្លួនក៏ជាជនរងគ្រោះដែលត្រូវបានឈ្មោះ [redacted] ចាន់ធឿន និងម៉ូវ ចាន់ថេន វាយបណ្តាលអោយមានរបួសដែរ ។

- បានស្តាប់ចម្លើយជនជាប់ចោទ
- បានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- បានស្តាប់ចម្លើយជនរងគ្រោះ
- បានស្តាប់ចម្លើយរបស់សាក្សី
- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- បានស្តាប់ជនជាប់ចោទនិយាយជាសំដីចុងក្រោយបង្អស់
- ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តតាកែវ

+ **យល់ឃើញថា** : កាលពីថ្ងៃទី ០៨ ខែ ០៣ ឆ្នាំ ២០១០ នៅភូមិអញ្ចាញ ឃុំជ័យជោគ ស្រុកបូរីជលសារ ខេត្តតាកែវ ពិតជាមានអំពើបង្ករបួសដែលបង្កឡើងដោយជនល្មើសឈ្មោះ [redacted] សក្កដា បានវាយទៅលើជនរងគ្រោះឈ្មោះ [redacted] ចាន់ធឿន និងឈ្មោះ [redacted] ចាន់ថេន ( ជាបងប្អូន ) បណ្តាលអោយមានរបួសប្រាកដមែន ។

+ **យល់ឃើញថា** : តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សក្កដា អះអាងថា នៅថ្ងៃកើតហេតុខាងលើខ្លួនពិតជាបានវាយតបទៅវិញទៅមកជាមួយឈ្មោះ [redacted] ចាន់ធឿន និងម៉ូវ ចាន់ថេន មែន នេះដោយសារ[illegible]

គេទាំងពីរនាក់បានជេរប្រមាថចំពោះខ្លួន ។ ហើយពេលប្រតាយប្រតប់គ្នាឈ្មោះ [redacted] ចាន់ថេន បានយកដែកម៉ាភ៉ាវែន ( គោយន្ត ) វាយចំក្បាលរបស់ខ្លួនទៀតផង ។

+ **យល់ឃើញថា** : ដីកាសំរេចលើកលែងចោទប្រកាន់លេខ ១៦៥ ចុះថ្ងៃទី ០៣ ខែ ០៥ ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរបានសម្រេចលើកលែងចោទប្រកាន់លើឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ [redacted] ចាន់ថេន ភេទប្រុស អាយុ២៣ឆ្នាំ ។

ពីបទ :បង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិអញ្ចាញ ឃុំជ័យជោគ ស្រុកបូរីជលសារ ខេត្តតាកែវ ។ តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

+ **យល់ឃើញថា** : តាមចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីបញ្ជាក់បានជាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សក្កដា ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិអញ្ចាញ ឃុំជ័យជោគ ស្រុកបូរីជលសារ ខេត្តតាកែវ កាលពីថ្ងៃទី ០៨ ខែ ០៣ ឆ្នាំ ២០១០ ។

- បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

+ **យល់ឃើញថា** : ដែកម៉ាភ៉ាវែនមួយគូគឺជាវត្ថុតាងនៃអំពើបង្ករបួសពិតប្រាកដមែន ។

+ **យល់ឃើញថា** : ព្យសនៈកម្មនៃអំពើរបស់ជនជាប់ចោទមានទំហំតិចតួច មិនប៉ះពាល់ធ្ងន់ធ្ងរដល់ជនរងគ្រោះឡើយ ។ ម្យ៉ាងទៀតជនជាប់ចោទជាជនក្រីក្រលំបាកតោកយ៉ាក ខ្វះការពិចារណា និងជាជនប្រព្រឹត្តបទល្មើសលើកដំបូង ។

+ **យល់ឃើញថា** : មាត្រា ១១៧,១១៨ នៃក្រមព្រហ្មទណ្ឌចែងអំពីការព្យួរទោសដើម្បីទុកឱកាសអោយអ្នកទោសកែប្រែខ្លួន ។

+ **យល់ឃើញថា** : ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានប្តឹងទាមទារថ្លៃព្យាបាល និងជម្ងឺចិត្តចំនួន ១០.០០០.០០០៛ ( ដប់លានរៀល ) តុលាការលើកយកបញ្ហានេះមកពិចារណាតាមសភាពជាក់ស្តែង ។

**ហេតុដូច្នេះវិនិច្ឆ័យសេចក្តី**

១/ ផ្តន្ទាទោសឈ្មោះ [redacted] សក្កដា ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ( មួយឆ្នាំ ) តែទោសនេះត្រូវព្យួរថេរវេលាសាកល្បង ០៣ឆ្នាំ ( បីឆ្នាំ ) គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

- ពីបទ : បង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិអញ្ចាញ ឃុំជ័យជោគ ស្រុកបូរីជលសារ ខេត្តតាកែវ កាលពីថ្ងៃទី ០៨ ខែ ០៣ ឆ្នាំ ២០១០ ( តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ១១៧,១១៨ នៃក្រមព្រហ្មទណ្ឌ ) ។

២/បង្គាប់អោយឈ្មោះ [redacted] សក្កដា សងសំណងការអន្តរាយ និងជម្ងឺចិត្តអោយទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ែអ ម៉ូរ៉ ចំនួន ២.០០០.០០០៛ ( ពីរលានរៀល ) ។ ការទាមទារលើសពីនេះលើកចោល ។

៣/ វត្ថុតាងដែលមានដែកម៉ាភ៉ាវែន ( គោយន្ត ) មួយគូត្រូវរឹបអូសបំផ្លាញចោល ។

Scanned with CamScanner

៤/ សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី**

ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជំរះ**

ហត្ថលេខា និងត្រា

[redacted]

---

**បានឃើញ**

ថ្ងៃទី.26...ខែ..6.....ឆ្នាំ២០១១

ចៅក្រមជំនុំជំរះ

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

តាកែវ.ថ្ងៃទី26..ខែ...6....ឆ្នាំ ២០១១

ក្រឡាបញ្ជី

[redacted]